00646785

E9/13

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (សម្ងាត់ចំពោះឧបសម្ព័ន្ធ១)

ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬអង្គជំនុំជម្រះ: សាធារណៈ / Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**សេចក្តីសង្ខេបអំពីអ្នកជំនាញ ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី របស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០**

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

ជនជាប់ចោទនិង មេធាវីការពារក្តីជនជាប់ចោទ:
នួន ជា
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
អៀង សារី
លោក អាង ឧត្តម
លោក Michael G.KARNAVAS
ខៀវ សំផន
លោក ស ស្វាន

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 23 / 02 / 2011
ម៉ោង (Time/Heure): 15:55
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

លោក Jacques VERGÈS

លោក Phillipe GRECIANO

**អៀង ធីរិទ្ធ**

លោក ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

## I. សេចក្តីផ្តើម

១. អនុលោមតាមអនុវិធាន ៨០.៣ នៃវិធានផ្ទៃក្នុង និងស្របតាម *ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ* របស់អង្គជំនុំជម្រះសាលាដំបូង[1] សហព្រះរាជអាជ្ញាសូមដាក់សេចក្តីសង្ខេបនៃសក្ខីកម្មដែលរំពឹងទុកសម្រាប់សាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញទាំងអស់ដែលបានស្នើឡើងដោយអង្គជំនុំជម្រះសាលាដំបូង។

## II. ខ្លឹមសារនៃសេចក្តីសង្ខេប

២. **ឧបសម្ព័ន្ធ ១** ជាឧបសម្ព័ន្ធសម្ងាត់ ជាតារាងមួយដែលចុះបញ្ជីឈ្មោះរបស់សាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ និងការផ្តល់សេចក្តីសង្ខេបដូចខាងក្រោម៖

ក. អង្គហេតុរំពឹងទុកដែលសាក្សីម្នាក់ៗនឹងផ្តល់សក្ខីកម្មជូន

ខ. អង្គហេតុដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗនឹងត្រូវបានស្តាប់

គ. គុណវុឌ្ឍិ និងជំនាញដែលបានស្នើឡើងរបស់អ្នកជំនាញម្នាក់ៗ ហើយនិង

ឃ. ចំណុចពាក់ព័ន្ធផ្សេងៗនៃដីកាដំណោះស្រាយ សម្រាប់សាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញម្នាក់ៗ ។

ដើម្បីងាយស្រួលធ្វើសេចក្តីយោង **ឧបសម្ព័ន្ធ១** ចុះឈ្មោះបុគ្គលម្នាក់ៗទាំងនេះតាមលំដាប់ដូចគ្នានឹងឧបសម្ព័ន្ធ១ នៃ *បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា* (បញ្ជីឈ្មោះតាមវិធាន៨០)[2]។

*ភាគីដើមបណ្តឹងរដ្ឋប្បវេណី - បច្ចុប្បន្នភាពអំពីឋានៈ*

---

[1] ដីកាបង្គាប់ឱ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ, អង្គជំនុំជម្រះសាលាដំបូង, ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១, E9 ។

[2] ឧបសម្ព័ន្ធ១ នៃបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨០, សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសដ, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១, E9/4.1 ។

៣. តាមការពិនិត្យថ្មីៗលើព័ត៌មានដែលមានស្រាប់នៅក្នុងសំណុំរឿង សហព្រះរាជអាជ្ញាបានរកឃើញថាបុគ្គលដែលមានលេខសម្គាល់ P-100 និង P-227 ដែលបានកំណត់ក្នុងបញ្ជីឈ្មោះតាមវិធាន ៨០ ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី (និងបុគ្គលដែលបានសម្ភាសដោយសហចៅក្រមស៊ើបអង្កេតថាជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី) តាមពិតពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេត្រូវបានប្រកាសថា មិនទទួលយកបានទេ។ ផ្ទុយទៅវិញ បុគ្គលដែលមានលេខសម្គាល់ P-218 ត្រូវបានទទួលស្គាល់ជា ភាគីដើមបណ្តឹងរដ្ឋប្បវេណី។ ការផ្លាស់ប្តូរនានាត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងឧបសម្ព័ន្ធ១ ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ ត្រូវបានដាក់សញ្ញាសម្គាល់ផ្កាយ[*] និងបានកំណត់ដូចនេះ នៅក្នុងសេចក្តីសង្ខេបរបស់ពួកគេរៀងៗខ្លួន។ សាក្សីអ្នកជំនាញត្រូវបានដាក់សញ្ញាសម្គាល់[#] ។

*ការធ្វើអត្តសញ្ញាណកម្មចំណុចនានានៃដីកាដំណោះស្រាយ និងការវាយតម្លៃសាក្សី*

៤. ចំណុចនានានៃដីកាដំណោះស្រាយដែលបានចុះបញ្ជីសម្រាប់សាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញម្នាក់ៗដែលបានស្នើឡើង ឆ្លុះបញ្ចាំងអំពីការបកស្រាយដោយសុចរិតរបស់សហព្រះរាជអាជ្ញា ចំពោះបទសម្ភាសន៍របស់បុគ្គលម្នាក់ៗទាំងនេះ ដែលបានធ្វើឡើងក្នុងពេលស៊ើបសួរ។ ខណៈដែលកិច្ចប្រឹងប្រែងនានាត្រូវបានធ្វើឡើង ដើម្បីកំណត់ចំណុចនានានៃដីកាដំណោះស្រាយដែលសក្ខីកម្មនិមួយៗពាក់ព័ន្ធនោះ កំណត់ហេតុស្តាប់ចម្លើយសាក្សី កំណត់ហេតុរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬកំណត់ហេតុរបស់អ្នកជំនាញ ទាំងសេចក្តីសង្ខេប ឬសម្ភារៈផ្សេងៗទៀតមិនអាចផ្តល់រឿងរ៉ាវសព្វគ្រប់អំពីអង្គហេតុភវនីយភាព ឬអង្គហេតុដែលពាក់ព័ន្ធទាំងអស់ ជាងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញអាចផ្តល់ជូនតុលាការបាន។ តាមស្មារតីនេះ សហព្រះរាជអាជ្ញាជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីដទៃទៀត ថាប្រសិនបើមានសក្ខីកម្មរបស់សាក្សី ភាគីដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញណាមួយមានលក្ខណៈច្បាស់លាស់ថាបុគ្គលរូបនោះអាចផ្តល់ភ័ស្តុតាងណាមួយទាក់ទិងនឹងផ្នែកនៃសំណុំរឿង ហើយដែលមិនបានកំណត់ច្បាស់លាស់នៅក្នុង "ចំណុចនានានៃដីកាដំណោះស្រាយ" ក្នុងឧបសម្ព័ន្ធ១ សហព្រះរាជអាជ្ញានឹងស្នើឱ្យបង្ហាញភ័ស្តុតាងនោះ បើសិនអាចជួយដល់អង្គជំនុំជម្រះសាលាដំបូងក្នុងការស្វែងរកការពិតអំពីអង្គហេតុនានាដូចបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

00646789



៥. នៅក្នុងការរៀបចំសេចក្តីសង្ខេបទាំងនេះ សហព្រះរាជអាជ្ញា មិនបានស្វែងរកធ្វើការវាយតម្លៃពីភាពគួរឱ្យជឿជាក់បានយ៉ាងជាក់ស្តែងពីបុគ្គលណាមួយនោះទេ ដោយគ្រាន់តែបញ្ជាក់ពីតួយ៉ាងនានានៅខណៈដែល៖

ក. សាក្សីណាម្នាក់ត្រូវបានកំណត់អត្តសញ្ញាណដោយប្រភពភស្តុតាងដទៃទៀត ថាបានកាន់កាប់មុខតំណែង ឬបានចូលរួមចំណែកនៅក្នុងព្រឹត្តិការណ៍នានា ដែលសាក្សីរូបនោះមិនបានទទួលស្គាល់(ហើយដូច្នេះ កាលណាសេចក្តីសង្ខេបចម្លើយដ៏សាមញ្ញរបស់សាក្សីនោះអាចបង្ហាញពីរូបភាពមិនត្រឹមត្រូវមួយ)។

ខ. វាមានលេចចេញពីចម្លើយនោះថា សាក្សីរូបនោះមិនរួមសហការដោយត្រឹមតែបានប្រកែកមិនព្រមចុះហត្ថលេខា ឬដោយផ្សេងពីនេះ បានស្តែងចេញនូវចរិតមិនរួមសហការជាមួយនឹងអង្គជំនុំជម្រះ។

## III. សាក្សី និងអ្នកជំនាញ ដែលមិនបានសម្ភាសដោយ កសចស

៦. អៀង សារី បានលើកសំអាងថា “ក.ស.ព មិនត្រូវអនុញ្ញាតអោយកោះហៅសាក្សី ដែល ក.ស.ច.ស មិនទាន់បានធ្វើការស្តាប់ចម្លើយក្នុងអំឡុងពេលស៊ើបអង្កេតរបស់តុលាការនោះទេ”[3]។ ពិតមែនហើយ ការហាមឃាត់ដែលមិនត្រឹមត្រូវ និងមិនមានហេតុផលនេះ វាសមស្របទៅនឹងផលប្រយោជន៍របស់គាត់ហើយ។ ការពឹងផ្អែករបស់ អៀង សារី ទៅលើវិធាន៨៧.៣ នៅក្នុងការអះអាងដោយឥតអៀនខ្មាសនេះ ត្រូវបានដាក់ខុសកន្លែង៖ លក្ខខណ្ឌតម្រូវដែលថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលមានមូលដ្ឋាននៅលើ *“ភស្តុតាងពីក្នុងសំណុំរឿង”* មិនបានធ្វើឱ្យស្មើនឹងវិធានមួយដែលថា មានតែភស្តុតាងដែលសហចៅក្រមស៊ើបអង្កេត បានដាក់ចូលទៅក្នុងសំណុំរឿងប៉ុណ្ណោះទេ ទើបអង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកទៅលើបាន។ និយាយពីការជាក់ស្តែង វិធានមួយបែបដូច្នេះ នឹងច្រានចោលជាមុននូវការផ្តល់សក្ខីកម្មផ្ទាល់ នៅចំពោះមុខអង្គជំនុំជម្រះសាលា

---

[3] ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន៨០, ថ្ងៃទី៨ កុម្ភៈ ២០១១, E9/4/1, កថាខណ្ឌទី១០។

ដំបូង ព្រោះថាប្រតិចារឹកនៃសវនាការ គឺតាមនិយមន័យ ថាត្រូវបានដាក់ចូលទៅក្នុងសំណុំរឿង *នៅក្រោយពេល* ការបិទការស៊ើបសួរ។

៧. បន្ថែមលើនេះ វាមិនមានអ្វីសោះនៅក្នុងភាសានៃវិធាន៨០ ឬ វិធាន៨៧ ដែលចែងពីវិធាននៃភ័ស្តុតាងដែលកំពុងនៅជាធរមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ដែលថានឹងកម្រិតពីប្រភេទនៃបុគ្គលទាំងឡាយដែលភាគីនានាអាចនឹងដាក់ស្នើធ្វើជាសាក្សីនៅពេលសវនាការនោះទេ។ តាមការពិត អនុវិធាន៨៧.១ បានចែងថា "លើកលែងតែមានបទប្បញ្ញត្តិផ្សេងក្នុងវិធានផ្ទៃក្នុងនេះ រាល់ភ័ស្តុតាងទាំងអស់ត្រូវតែទទួលយក"។ បន្ទាប់មក អនុវិធាន៨៧.៣ បានចែងពីទឡ្ហីករណ៍ជាក់លាក់នានាដែលគេ *អាចនឹង* បដិសេធចំពោះភស្តុតាងបាន។ សហព្រះរាជអាជ្ញា សន្និដ្ឋានថាដរាបណា អង្គជំនុំជម្រះមានការយល់ឃើញថា តាមមូលដ្ឋាន*ឃើញតែមួយក្រឡេកភ្នែក* សក្ខីកម្មរបស់សាក្សីណាម្នាក់ដែលបានស្នើឡើង ត្រូវទៅតាមលក្ខខណ្ឌវិនិច្ឆ័យ ដែលមានចែងនៅក្នុងវិធាន ៨៧ ដរាបនោះគឺត្រូវបើកចំហរដល់អង្គជំនុំជម្រះនេះ ដើម្បីអនុវត្តនូវឆន្ទានុសិទ្ធិរបស់ខ្លួនក្នុងការកោះហៅសាក្សីរូបណាមួយ។

៨. ការបកស្រាយខាងលើនេះត្រូវបានគាំទ្របន្ថែមដោយអនុវិធាន ៨៧.៤ ដែលចែងថា ក្នុងអំឡុងពេលសវនាការ "អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកភ័ស្តុតាងថ្មីដែលមានផលប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត"។ ជាការច្បាស់ណាស់ថា បើសិន "ជនណាម្នាក់" អាចត្រូវបានកោះហៅឱ្យមកធ្វើជាសាក្សីនៅក្នុងពេលសវនាការ, *ដោយមូលហេតុពិសេសជាងនេះទៅទៀត* ភាគីនានា តែងតែមានលទ្ធភាពអាចស្នើឱ្យបុគ្គលណាម្នាក់ធ្វើជាសាក្សីបាននៅមុនពេលសវនាការចាប់ផ្តើម។ តាមពិតទៅ ផលប្រយោជន៍នៃការធ្វើសវនាការដោយប្រសិទ្ធភាព ក្នុងការស្រាយបញ្ជាក់គាំទ្រដល់ការធ្វើអត្តសញ្ញាណកម្ម និងការធ្វើសំណើសុំសាក្សីបន្ថែមដោយភាគីនានា នៅមុនការចាប់ផ្តើមសវនាការ ដែលហេតុដូចនេះជាការកាត់បន្ថយភាពចាំបាច់ក្នុងការពឹងផ្អែកទៅលើវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុង។ អៀង សារី ក៏បានជជែកតវ៉ាផងដែរថា ការអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាកោះហៅសាក្សីនានា ដែលសហចៅក្រមស៊ើបអង្កេត ("កសចស") មិនបានស្តាប់ចម្លើយពួកគេនោះ គឺជាការ "រកផ្លូវជៀសពីសិទ្ធិអំណាចរបស់ កសចស"[4]។ ផ្ទុយពីសេចក្តីសន្និដ្ឋាននេះ កសចស បានសម្រេចនៅក្នុងដីកា

[4] ដូចគ្នានឹងខាងលើ។

សម្រេចមួយចំនួនដែលបានបដិសេធលើសំណើរបស់ភាគីនានា ដែលសុំស្តាប់ចម្លើយរបស់បុគ្គលមួយចំនួនដែលភាគីនានាត្រូវបានអនុញ្ញាតឱ្យមានសិទ្ធិអាចស្នើសុំឱ្យបុគ្គលទាំងនោះធ្វើជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន បើសិនជាជនជាប់ចោទ(នៅពេលនោះ)ត្រូវបានចេញដីកាបញ្ជូនទៅជំនុំជម្រះ[5]។

៩. ស្រដៀងគ្នានេះដែរ ការអះអាងរបស់ អៀង សារី ដែលថា អ្នកជំនាញថ្មីៗដែលបានស្នើសុំ "គួរតែត្រូវបានអនុញ្ញាតឱ្យធ្វើ... បើសិនជាពួកគេត្រូវបានកោះហៅឱ្យមកធ្វើការពន្យល់ និងបកស្រាយនូវចម្លើយដែលបានធ្វើឡើង នៅក្នុងការចេញផ្សាយរបស់ពួកគេដែលមាននៅក្នុងសំណុំរឿងស្រាប់ហើយ"[6] ដែលរកទៅមិនឃើញមានការគាំទ្រណាមួយនៅក្នុងវិធានផ្ទៃក្នុង និងដែលមិនមានភាពស្របគ្នាទៅនឹងទម្លាប់ការអនុវត្តន៍របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ០០១ បើសិនជាសក្ខីកម្មរបស់អ្នកជំនាញទាំងបីនាក់ដែលមិនត្រូវបានស្តាប់ចម្លើយដោយ កសចស (ដែលមានលោក ណាយ៉ាន់ ចាន់ដា, ដេវីដ ឆាន់ដល័រ និងលោក ខ្មេក អ៊ែតឈីសិន) មិនត្រូវបានកម្រិតកំណត់តាមវិធីដែលត្រូវបានដាក់ជូនដោយ អៀង សារី ក្នុងពេលនេះ។

១០. សហព្រះរាជអាជ្ញាធ្វើការកត់សំគាល់ថា ជនជាប់ចោទបានលើកឡើងនូវបញ្ហាផ្សេងៗទៀតជាច្រើនដែលទាក់ទងនឹងសាក្សី នៅក្នុងការដាក់សំណើរបស់ខ្លួន ដែលក្នុងនោះរួមទាំងចម្លើយរបស់ នួន ជា ដែលគាត់មានបំណងកោះហៅឱ្យមកធ្វើសាក្សីនូវ "បុគ្គលម្នាក់ៗគ្រប់គ្នាទាំងអស់" ដូចដែលមានឈ្មោះនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរណាមួយ ដែលត្រូវបានទទួលយកជាភ័ស្តុតាង[7]។ ដើម្បីជាប្រយោជន៍ដល់ការសន្សំសំចៃថវិការបស់តុលាការ សហព្រះរាជអាជ្ញាកម្រិតនូវសេចក្តីសន្និដ្ឋានរបស់ខ្លួន ក្នុងការដាក់ឯកសារនេះ ត្រឹមតែទឡ្ហីករណ៍ផ្សេងៗដែលជាប់ពាក់ព័ន្ធផ្ទាល់ទៅនឹងការដាក់បញ្ចូលនូវបុគ្គលមួយចំនួននៅក្នុងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ ដែលបានស្នើសុំ។ សហព្រះរាជអាជ្ញាស្នើឱ្យធ្វើការដោះស្រាយចំពោះបញ្ហា

---

[5] ដីកាសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមស្តីពីជនត្រូវចោទ អៀង ធីរិទ្ធ, របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី២ មេសា ២០១០, ឯកសារលេខ D350/1, កថាខណ្ឌទី១២។ ដីកាសម្រេចលើសំណើសុំកិច្ចស៊ើបសួរ លើកទីដប់ប្រាំបីរបស់ នួន ជា ចុះថ្ងៃទី១៧ កុម្ភៈ ២០១០, ឯកសារលេខ D273/2, កថាខណ្ឌទី៩។ ដីកាសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា សុំឱ្យបំពេញកិច្ចស៊ើបសួរ ស្តីពីជនត្រូវចោទ នួន ជា, ចុះថ្ងៃទី៣១ មីនា ២០១០, ឯកសារលេខ D342/1, កថាខណ្ឌទី៦។

[6] ចម្លើយតបរបស់ អៀង សារី ទៅនឹងញត្តិស្នើសុំរបស់សហព្រះរាជអាជ្ញា ដែលអមជាមួយនឹងបញ្ជីឈ្មោះសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញ អនុលោមតាមវិធាន៨០ នៃវិធានផ្ទៃក្នុង, ចុះថ្ងៃទី៨ កុម្ភៈ២០១១, ឯកសារលេខ E9/4/1, កថាខណ្ឌទី១០។

[7] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និង ដើមបណ្តឹងរដ្ឋប្បវេណី ចុះថ្ងៃទី១៥ កុម្ភៈ ២០១១, ឯកសារលេខ E9/4/4។

នានាដែលនៅសេសសល់ទាក់ទងនឹងសាក្សី នៅក្នុងកិច្ចប្រជុំស្តីពីការរៀបចំសវនាការនាពេលខាងមុខឆាប់ៗនេះ។

១១. តាមការណែនាំរបស់អង្គជំនុំជម្រះសាលាដំបូង សហព្រះរាជអាជ្ញានឹងដាក់ជូនឧបសម្ព័ន្ធនេះ ជា Microsoft Word Version ដាច់ដោយឡែក៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ | **លោក យ៉េត ចរិយា** សហព្រះរាជអាជ្ញារង | CO-PROSECUTORS CO-PROCUREURS E.C.C.C. | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |